# សេចក្តីណែនាំ សំរាប់ការបំពេញ តារាងឯកសារការថែទាំក្មេង
## INSTRUCTIONS FOR COMPLETING THE CHILD CARE RECORD CHART (Khmer)

សេចក្តីណែនាំទាំងនេះ គឺដើម្បីជួយអ្នកក្នុងការបំពេញ តារាងឯកសារការថែទាំក្មេង (សូមមើលតារាងមានភ្ជាប់មកជាមួយ) ។ សំណៅនៃតារាងបច្ចុប្បន្ន គួរតែបានបញ្ជូនទៅអ្នកចេញសំបុត្រអនុញ្ញាត នៅថ្ងៃនៃការមកមើល ។ ទុកកន្លែងនៅលើតារាងឲ្យនៅទំនេរ ដើម្បីបញ្ជាក់ថាព័ត៌មានមិននៅក្នុងឯកសាររបស់ក្មេងទេ ។

**1. ឈ្មោះរបស់ក្មេង, អាសយដ្ឋាន, លេខទូរស័ព្ទផ្ទះ និងឈ្មោះរបស់ឪពុកម្តាយ ។** កត់ឈ្មោះក្មេងៗទាំងអស់ តាមឈ្មោះពេញច្បាប់របស់គេ ព្រមទាំងអាសយដ្ឋានផ្ទះ លេខទូរស័ព្ទផ្ទះ និងក៏កត់ឈ្មោះឪពុកម្តាយរបស់គេដែរ ។

**2. វត្តមានមុខ នៅពេលមកមើល ។** អ្នកចេញសំបុត្រអនុញ្ញាត នឹងបំពេញផ្នែកនេះ នៅពេលមកមើល ។

**3. ខែថ្ងៃឆ្នាំអនុញ្ញាតឲ្យចូលមក ។** កត់ខែថ្ងៃឆ្នាំ ដែលក្មេងបានមកកន្លែងថែទាំ ជាលើកដំបូងបង្អស់ ។

**4. ខែថ្ងៃឆ្នាំកំណើត ។** កត់ខែថ្ងៃឆ្នាំកំណើតរបស់ក្មេង ។

**5. ពេលម៉ោង/ថ្ងៃ មកដល់ និងចេញទៅវិញ ។** កត់ពេលម៉ោង និងថ្ងៃបច្ចុប្បន្ន នៃការមកដល់ និងចេញទៅវិញ ដែលក្មេងមកកន្លែងថែទាំ ។

**6. លេខទូរស័ព្ទពេលថ្ងៃរបស់ឪពុកម្តាយ ។** កត់លេខទូរស័ព្ទរបស់ឪពុកម្តាយ សំរាប់ទាក់ទងពេលថ្ងៃ ។

**7. សភាពការណ៍ប្រចាំឆ្នាំ ។** បញ្ជាក់ដោយគំនូស ថាឯកសាររបស់ក្មេងបានកែឲ្យទាន់សភាពការណ៍ជាប្រចាំឆ្នាំ បន្ទាប់ពីការពិនិត្យមើលឡើងវិញ នូវឯកសាររបស់ក្មេង ជាមួយនឹងឯកសាររបស់ឪពុកម្តាយ ។

**8. មនុស្សទាក់ទងនៅគ្រាអាសន្ន ។** បញ្ជាក់ដោយគំនូស ថាឈ្មោះ អាសយដ្ឋាន និងលេខទូរស័ព្ទរបស់មនុស្ស ដើម្បីទាក់ទងនៅក្នុងករណីមានអាសន្ន នៅពេលមិនអាចទាក់ទងឪពុកម្តាយ បានកត់នៅត្រង់នេះ ។

**9. មនុស្សមកយកបានអនុញ្ញាត ។** បញ្ជាក់ដោយគំនូស ថាឈ្មោះ អាសយដ្ឋាន និងលេខទូរស័ព្ទរបស់មនុស្សដែលបានអនុញ្ញាតដើម្បីយកក្មេងចេញពីផ្ទះគ្រួសារថែទាំក្មេង បានកត់នៅត្រង់នេះ ។

**10. កាលវិភាគ និងចំណង់ចិត្ត ។** បញ្ជាក់ដោយគំនូស ថាក្រដាសបំពេញកាលវិភាគ និងចំណង់ចិត្តរបស់ក្មេង បានបំពេញដោយឪពុកម្តាយ ។

**11. ការអនុញ្ញាតទូទៅ ។** បញ្ជាក់ដោយគំនូស ថាការអនុញ្ញាតជាទូទៅប្រចាំឆ្នាំ ដោយលាយលក្ខណ៍អក្សរ បានបំពេញ បានចុះហត្ថលេខា និងបានចុះខែថ្ងៃឆ្នាំ ដោយឪពុកម្តាយ ។ ក្រដាសបំពេញនេះផ្តល់ការអនុញ្ញាតឲ្យអ្នកថែរក្សា ឲ្យអាចយកក្មេងចេញពីទីបរិវេណនៃផ្ទះគ្រួសារថែទាំក្មេង ព្រមទាំងកត់ដំណើរកំសាន្តជាទូទៅ និងមធ្យោបាយនៃយានជំនិះ ។

**12. ឪពុកម្តាយមកមើល ។** បញ្ជាក់ដោយគំនូស ថាបានជំរាបឪពុកម្តាយ ថាគេអាចមកមើលផ្ទះគ្រួសារថែទាំក្មេងបាន ដោយឥតប្រាប់ដំណឹងជាមុន នៅពេលណាក៏បាន ក្នុងកំឡុងម៉ោងដែលកូនរបស់គេនៅកន្លែងថែទាំ ហើយថា ឪពុកម្តាយបានចុះហត្ថលេខាលើក្រដាសបំពេញនូវការបញ្ជាក់ ថាគេបានទទួលសេចក្តីជំរាបនេះ ។

**13. ក្រដាសបំពេញ សុខភាពជាអាសន្ន ។** បញ្ជាក់ដោយគំនូស ថាមានការអនុញ្ញាជាប្រចាំឆ្នាំដោយលាយលក្ខណ៍អក្សរ ដើម្បីដឹកកូនទៅមន្ទីរពេទ្យ និងសំរាប់ឲ្យក្មេងទទួលការព្យាបាលសុខភាពជាអាសន្ន នៅក្នុងព្រឹត្តិការណ៍ដែលមិនអាចទាក់ទងឪពុកម្តាយបាន ហើយបើមានការពន្យារពេល នឹងធ្វើឲ្យគ្រោះថ្នាក់ដល់សុខភាពរបស់ក្មេង ។ ការអនុញ្ញាតនេះ ក៏ត្រូវតែផ្តល់ការអនុញ្ញាតជាលាយលក្ខណ៍ក្សរ សំរាប់អ្នកថែរក្សាផ្តល់ CPR (ការជួយផ្លុំដង្ហើមខ្យល់ឲ្យដើរវិញ) និងជំនួយសង្គ្រោះបន្ទាន់ដែរ ។

**14. ការថែទាំសុខភាព ។** បញ្ជាក់ដោយគំនូស ថាឪពុកម្តាយបានកត់គ្រូពេទ្យកុមាររបស់ក្មេង ឬប្រភពការថែទាំសុខភាព នៅក្នុងសំណុំរឿង (ឈ្មោះ អាសយដ្ឋាន និងលេខទូរស័ព្ទ) ។

**15. ក្រដាសព័ត៌មានពិត អំពីឪពុកម្តាយ ។** បញ្ជាក់ដោយគំនូស ថាឪពុកម្តាយបានទទួលសំណៅនៃក្រដាសព័ត៌មានពិតអំពីឪពុកម្តាយ ព្រមទាំងបានចុះហត្ថលេខាលើក្រដាសបំពេញ ដោយមានការបញ្ជាក់ថាគេបានទទួលវា ។

**16. របាយការណ៍ពេទ្យ ។** បញ្ជាក់ដោយគំនូស ថាសេចក្តីថ្លែងការណ៍ បានចុះហត្ថលេខា ព្រមទាំងបានចុះខែថ្ងៃឆ្នាំផង ដោយវេជ្ជបណ្ឌិត ឬភ្នាក់ងារថែទាំសុខភាព ដែលបានពិនិត្យក្មេង នៅក្នុងរយៈពេលមួយឆ្នាំ មុនពេលអនុញ្ញាតឲ្យចូលមក ថាលក្ខណៈពិសេសអ្វីមួយដែលបានដឹង គឺកំពុងតែបានព្យាបាល ទាំងមានការបញ្ជាក់នូវប្រតិកម្មនឹងវត្ថុធាតុទាំងអស់ ឬមានលក្ខណៈផ្សេងៗទៀត ដែលនឹងត្រូវការថែទាំពិសេស ។ ការពិនិត្យសុខភាពកាយ គួរតែប្រើការបានចំនួនមួយឆ្នាំ ចាប់តាំងពីខែថ្ងៃឆ្នាំដែលក្មេងបានទទួលពិនិត្យ ហើយគប្បីតែបានពិនិត្យសាឡើងវិញជាប្រចាំឆ្នាំ បន្ទាប់ពីពេលនោះមក ។

**17. ការចាក់ថ្នាំបង្ការរោគ ។** បញ្ជាក់ដោយគំនូស ថាសេចក្តីថ្លែងការណ៍ បានចុះហត្ថលេខា ព្រមទាំងបានចុះខែថ្ងៃឆ្នាំផង ដោយវេជ្ជបណ្ឌិត ឬភ្នាក់ងារថែទាំសុខភាព ថាក្មេងបានចាក់ថ្នាំបង្ការរោគគ្រប់ទាំងអស់ ដោយស្របទៅតាមកាលវិភាគបច្ចុប្បន្ន ដែលក្រសួងសុខភាពសាធារណៈ បានឲ្យយោបល់ ។ អ្នកថែរក្សា ត្រូវរក្សាឯកសារការចាក់ថ្នាំបង្ការរបស់ក្មេង ឲ្យទាន់សភាពការណ៍ ដោយស្របទៅតាមកាលវិភាគបច្ចុប្បន្ន ដែលក្រសួងសុខភាពសាធារណៈ បានឲ្យយោបល់ ។

**18. ពិនិត្យសាកជាតិសំណ ។** បញ្ជាក់ដោយគំនូស ថាសេចក្តីថ្លែងការណ៍ បានចុះហត្ថលេខា ព្រមទាំងបានចុះខែថ្ងៃឆ្នាំ ដោយវេជ្ជបណ្ឌិត ឬបុគ្គលិកនៃភ្នាក់ងារថែទាំសុខភាព ដែលថ្លែងថាក្មេង (អាយុប្រាំបួនខែ ឬចាស់ជាង) បានត្រួតពិនិត្យមើលរកការពុលជាតិសំណ និងបានធ្វើជាប្រចាំឆ្នាំបន្ទាប់ពីពេលនោះមក រហូតទាល់តែមានអាយុបួនឆ្នាំ ។